ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២១៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## របបស្តីពីការសុំច្បាប់និងការអនុញ្ញាតច្បាប់ឈប់គ្រប់ប្រភេទ របស់មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៩និងមាត្រា១០នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះ មានគោលបំណងធានានិរន្តរភាពការងារ ការគ្រប់គ្រង និងការលើកកម្ពស់សុខុមាលភាពមន្ត្រីរាជការស៊ីវិលប្រកបដោយប្រសិទ្ធភាព។

**មាត្រា ២.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីរបបស្ដីពីការសុំច្បាប់និងការអនុញ្ញាតច្បាប់ឈប់គ្រប់ប្រភេទរបស់មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះមន្ត្រីរាជការស៊ីវិលដែលស្ថិតក្រោមច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៤.-**

វាក្យសព្ទបច្ចេកទេសសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះមាននិយមន័យដូចខាងក្រោម៖

- ច្បាប់ឈប់ប្រចាំឆ្នាំ សំដៅដល់ការអនុញ្ញាតឱ្យឈប់ដោយផ្អែកលើសិទ្ធិរបស់មន្ត្រីរាជការស៊ីវិលបន្ទាប់ពីបានតាំងស៊ប់ក្នុងក្របខ័ណ្ឌ។
- ច្បាប់ឈប់រយៈពេលខ្លី សំដៅដល់ការអនុញ្ញាតឱ្យឈប់ដោយផ្អែកលើមូលហេតុពិតប្រាកដ ដូចជាការរៀបអាពាហ៍ពិពាហ៍ ការព្យាបាលជំងឺ ការចូលរួមមរណទុក្ខជាដើម។
- ច្បាប់ឈប់សម្រាកលំហែមាតុភាព សំដៅដល់ការអនុញ្ញាតឱ្យឈប់ដោយផ្អែកលើសិទ្ធិរបស់មន្ត្រីរាជការស៊ីវិលជាស្ត្រីមុននិង/ឬក្រោយពេលសម្រាល។
- ច្បាប់ឈប់សម្រាកព្យាបាលជំងឺ សំដៅដល់ការអនុញ្ញាតឱ្យឈប់ចំពោះមន្ត្រីរាជការស៊ីវិលដែលមានជំងឺរ៉ាំរ៉ៃត្រូវការរយៈពេលឈប់សម្រាកព្យាបាលតាមវេជ្ជបញ្ជានៃគ្រូពេទ្យមានសមត្ថកិច្ច។
- ច្បាប់ឈប់សម្រាកដោយមានកិច្ចការផ្ទាល់ខ្លួន សំដៅដល់ការអនុញ្ញាតឱ្យឈប់ចំពោះមន្ត្រីរាជការស៊ីវិលដែលត្រូវការពេលវេលាដើម្បីការពារផលប្រយោជន៍ផ្ទាល់ខ្លួនឬគ្រួសារ។

## ជំពូកទី២
## ច្បាប់ឈប់ប្រចាំឆ្នាំ

**មាត្រា ៥.-**

មន្ត្រីរាជការស៊ីវិលដែលបានតាំងស៊ប់ក្នុងក្របខ័ណ្ឌ មានសិទ្ធិទទួលបានច្បាប់ឈប់ប្រចាំឆ្នាំចំនួន១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការក្នុង១(មួយ)ឆ្នាំ។ មន្ត្រីរាជការស៊ីវិលអាចទទួលបានច្បាប់ឈប់ប្រចាំឆ្នាំចំនួន៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ ប្រសិនបើមន្ត្រីរាជការស៊ីវិលនោះបានបម្រើការងារចំនួន២(ពីរ)ឆ្នាំជាប់គ្នា។

រយៈពេលឈប់នេះត្រូវបានកាត់បន្ថយទៅតាមចំនួនសមាមាត្រចំពោះមន្ត្រីរាជការស៊ីវិលដែលអនុវត្តច្បាប់ឈប់សម្រាកដោយមានកិច្ចការផ្ទាល់ខ្លួន ឬច្បាប់ឈប់សម្រាកព្យាបាលជំងឺ ឬស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សតាមពាក្យស្នើសុំក្នុងអំឡុងពេលខាងលើ។

មន្ត្រីរាជការស៊ីវិលអាចស្នើសុំច្បាប់ឈប់ប្រចាំឆ្នាំនេះមួយលើកឬច្រើនលើក។

**មាត្រា ៦.-**

ច្បាប់ឈប់ប្រចាំឆ្នាំត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឱ្យឈប់ដូចខាងក្រោម៖

ក. ចំពោះមន្ត្រីរាជការស៊ីវិលថ្នាក់រាជធានី ខេត្ត៖

- អភិបាលរាជធានី ខេត្ត ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឱ្យឈប់ពីរដ្ឋមន្ត្រី[illegible]

- អភិបាលរងរាជធានី ខេត្ត មន្ត្រីបម្រើការងារក្នុងរចនាសម្ព័ន្ធសាលារាជធានី ខេត្ត និងអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឱ្យឈប់ពីអភិបាលរាជធានី ខេត្ត
- អភិបាលរងក្រុង ស្រុក ខណ្ឌ មន្ត្រីបម្រើការងារក្នុងរចនាសម្ព័ន្ធសាលាក្រុង ស្រុក ខណ្ឌ ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឱ្យឈប់ពីអភិបាលក្រុង ស្រុក ខណ្ឌ
- ប្រធានមន្ទីរជំនាញរាជធានី ខេត្ត ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឱ្យឈប់ពីក្រសួង ស្ថាប័ន តាមរយៈអភិបាលរាជធានី ខេត្ត
- អនុប្រធានមន្ទីរជំនាញរាជធានី ខេត្ត មន្ត្រីបម្រើការងារក្នុងរចនាសម្ព័ន្ធមន្ទីរជំនាញរាជធានី ខេត្ត និងប្រធានការិយាល័យជំនាញក្រុង ស្រុក ខណ្ឌ ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឱ្យឈប់ពីប្រធានមន្ទីរជំនាញរាជធានី ខេត្ត
- អនុប្រធានការិយាល័យជំនាញក្រុង ស្រុក ខណ្ឌ មន្ត្រីបម្រើការងារក្នុងការិយាល័យជំនាញក្រុង ស្រុក ខណ្ឌ ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឱ្យឈប់ពីប្រធានការិយាល័យជំនាញក្រុង ស្រុក ខណ្ឌ។

ខ. ចំពោះមន្ត្រីរាជការស៊ីវិលថ្នាក់ជាតិ ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឱ្យឈប់ពីថ្នាក់ដឹកនាំក្រសួង ស្ថាប័ន។

រាល់ច្បាប់ឈប់ប្រចាំឆ្នាំដែលអនុញ្ញាតរួចហើយ ត្រូវជូនព័ត៌មានដល់មន្ត្រីទទួលបន្ទុកគ្រប់គ្រងបុគ្គលិកនៃអង្គភាពឬក្រសួង ស្ថាប័នរបស់ខ្លួន។

**មាត្រា ៧.-**

មន្ត្រីទទួលបន្ទុកគ្រប់គ្រងបុគ្គលិកនៃអង្គភាពឬក្រសួង ស្ថាប័ន ត្រូវរៀបចំបញ្ជីផែនការឈប់ប្រចាំឆ្នាំរបស់មន្ត្រីរាជការស៊ីវិលឱ្យបានសមស្របដើម្បីធានាឱ្យសកម្មភាពការងារនៃអង្គភាពឬក្រសួង ស្ថាប័នប្រព្រឹត្តទៅជាធម្មតា។

មន្ត្រីរាជការស៊ីវិលដែលជាគ្រូបង្រៀនឬសាស្ត្រាចារ្យ ត្រូវសុំច្បាប់ឈប់ប្រចាំឆ្នាំរបស់ខ្លួនឱ្យចំពេលវិស្សមកាល។

## ជំពូកទី៣
## ច្បាប់ឈប់រយៈពេលខ្លី

**មាត្រា ៨.-**

មន្ត្រីរាជការស៊ីវិលទាំងអស់មានសិទ្ធិស្នើសុំច្បាប់ឈប់រយៈពេលខ្លីសរុបចំនួន១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការក្នុង១(មួយ)ឆ្នាំ។

ក្នុងករណីចាំបាច់ មន្ត្រីរាជការស៊ីវិលអាចទទួលបានការអនុញ្ញាតច្បាប់ឈប់លើសពី១៥(ដប់ប្រាំ)ថ្ងៃ ប៉ុន្តែចំនួនថ្ងៃដែលលើសនោះត្រូវយកទៅកាត់ចេញពីចំនួនថ្ងៃនៃច្បាប់ឈប់ប្រចាំឆ្នាំ។

**មាត្រា ៩.-**

ច្បាប់ឈប់រយៈពេលខ្លី ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឱ្យឈប់ដូចខាងក្រោម៖

១. ពី១(មួយ)ថ្ងៃដល់៥(ប្រាំ)ថ្ងៃ ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឱ្យឈប់ពីប្រធានអង្គភាពដែលគ្រប់គ្រងផ្ទាល់ លើកលែងតែ៖

- អភិបាលរាជធានី ខេត្ត ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឱ្យឈប់ពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឱ្យឈប់ពីអភិបាលរាជធានី ខេត្ត

- ប្រធានមន្ទីរជំនាញរាជធានី ខេត្ត ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឱ្យឈប់ពីអភិបាលរាជធានី ខេត្ត ដោយជូនដំណឹងទៅក្រសួង ស្ថាប័នរបស់ខ្លួន។

២. ពី៦(ប្រាំមួយ)ថ្ងៃឡើងទៅ ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឱ្យឈប់ដូចតទៅ៖

ក. ចំពោះមន្ត្រីរាជការស៊ីវិលថ្នាក់រាជធានី ខេត្ត៖

- អភិបាលរាជធានី ខេត្ត ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឱ្យឈប់ពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- អភិបាលរងរាជធានី ខេត្ត មន្ត្រីបម្រើការងារក្នុងរចនាសម្ព័ន្ធសាលារាជធានី ខេត្ត និងអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឱ្យឈប់ពីអភិបាលរាជធានី ខេត្ត
- អភិបាលរងក្រុង ស្រុក ខណ្ឌ មន្ត្រីបម្រើការងារក្នុងរចនាសម្ព័ន្ធសាលាក្រុង ស្រុក ខណ្ឌ ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឱ្យឈប់ពីអភិបាលក្រុង ស្រុក ខណ្ឌ
- ប្រធានមន្ទីរជំនាញរាជធានី ខេត្ត ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឱ្យឈប់ពីក្រសួង ស្ថាប័ន តាមរយៈអភិបាលរាជធានី ខេត្ត
- អនុប្រធានមន្ទីរជំនាញរាជធានី ខេត្ត មន្ត្រីបម្រើការងារក្នុងរចនាសម្ព័ន្ធមន្ទីរជំនាញរាជធានី ខេត្ត និងប្រធានការិយាល័យជំនាញក្រុង ស្រុក ខណ្ឌ ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឱ្យឈប់ពីប្រធានមន្ទីរជំនាញរាជធានី ខេត្ត
- អនុប្រធានការិយាល័យជំនាញក្រុង ស្រុក ខណ្ឌ មន្ត្រីបម្រើការងារក្នុងការិយាល័យជំនាញក្រុង ស្រុក ខណ្ឌ ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឱ្យឈប់ពីប្រធានការិយាល័យជំនាញក្រុង ស្រុក ខណ្ឌ។

ខ. ចំពោះមន្ត្រីរាជការស៊ីវិលថ្នាក់ជាតិ ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឱ្យឈប់ពីថ្នាក់ដឹកនាំក្រសួង ស្ថាប័ន។

រាល់ច្បាប់ឈប់រយៈពេលខ្លីដែលអនុញ្ញាតរួចហើយ ត្រូវជូនព័ត៌មានដល់មន្ត្រីទទួលបន្ទុកគ្រប់គ្រងបុគ្គលិកនៃអង្គភាព ឬក្រសួង ស្ថាប័នរបស់ខ្លួន។

## ជំពូកទី៤
## ច្បាប់ឈប់សម្រាកលំហែមាតុភាព

**មាត្រា ១០.-**

មន្ត្រីរាជការស៊ីវិលជាស្ត្រី ត្រូវបានអនុញ្ញាតច្បាប់ឈប់សម្រាកលំហែមាតុភាពរយៈពេល៣(បី)ខែ។ ពាក្យស្នើសុំច្បាប់ឈប់សម្រាកលំហែមាតុភាពត្រូវភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់ពីគ្រូពេទ្យមានសមត្ថកិច្ច។

**មាត្រា ១១.-**

ច្បាប់ឈប់សម្រាកលំហែមាតុភាព ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឱ្យឈប់ដូចខាងក្រោម៖

ក. ចំពោះមន្ត្រីរាជការស៊ីវិលថ្នាក់រាជធានី ខេត្ត៖

- អភិបាលរាជធានី ខេត្ត ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឱ្យឈប់ពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- អភិបាលរងរាជធានី ខេត្ត មន្ត្រីបម្រើការងារក្នុងរចនាសម្ព័ន្ធសាលារាជធានី ខេត្ត និងអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឱ្យឈប់ពីអភិបាលរាជធានី ខេត្ត

- អភិបាលរងក្រុង ស្រុក ខណ្ឌ មន្ត្រីបម្រើការងារក្នុងរចនាសម្ព័ន្ធសាលាក្រុង ស្រុក ខណ្ឌ ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឱ្យឈប់ពីអភិបាលក្រុង ស្រុក ខណ្ឌ
- ប្រធានមន្ទីរជំនាញរាជធានី ខេត្ត ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឱ្យឈប់ពីក្រសួង ស្ថាប័ន តាមរយៈអភិបាលរាជធានី ខេត្ត
- អនុប្រធានមន្ទីរជំនាញរាជធានី ខេត្ត មន្ត្រីបម្រើការងារក្នុងរចនាសម្ព័ន្ធមន្ទីរជំនាញរាជធានី ខេត្ត និងប្រធានការិយាល័យជំនាញក្រុង ស្រុក ខណ្ឌ ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឱ្យឈប់ពីប្រធានមន្ទីរជំនាញរាជធានី ខេត្ត
- អនុប្រធានការិយាល័យជំនាញក្រុង ស្រុក ខណ្ឌ មន្ត្រីបម្រើការងារក្នុងការិយាល័យជំនាញក្រុង ស្រុក ខណ្ឌ ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឱ្យឈប់ពីប្រធានការិយាល័យជំនាញក្រុង ស្រុក ខណ្ឌ។

ខ. ចំពោះមន្ត្រីរាជការស៊ីវិលថ្នាក់ជាតិ ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឱ្យឈប់ពីថ្នាក់ដឹកនាំក្រសួង ស្ថាប័ន។

រាល់ច្បាប់ឈប់សម្រាកលំហែមាតុភាពដែលអនុញ្ញាតរួចហើយ ត្រូវជូនព័ត៌មានដល់មន្ត្រីទទួលបន្ទុកគ្រប់គ្រងបុគ្គលិកនៃអង្គភាពឬក្រសួង ស្ថាប័នរបស់ខ្លួន។

## ជំពូកទី៥
## ច្បាប់ឈប់សម្រាកព្យាបាលជំងឺ

**មាត្រា ១២.-**

ច្បាប់ឈប់សម្រាកព្យាបាលជំងឺ ត្រូវបានអនុញ្ញាតឱ្យមន្ត្រីរាជការស៊ីវិលពី១(មួយ)ខែទៅ៣(បី)ខែក្នុងមួយលើក បើពិនិត្យឃើញថាមានជំងឺមិនអាចមកបម្រើការងារបាន។ ច្បាប់ឈប់សម្រាកព្យាបាលជំងឺនិងច្បាប់សុំបន្តទៅទៀតអាចអនុញ្ញាតឱ្យបាន លុះត្រាតែមានលិខិតបញ្ជាក់ពីគ្រូពេទ្យមានសមត្ថកិច្ច ហើយច្បាប់នេះមានរយៈពេលសរុបមិនលើសពី១២(ដប់ពីរ)ខែក្នុងអំឡុងបម្រើការងារជាមន្ត្រីរាជការស៊ីវិល។

**មាត្រា ១៣.-**

ច្បាប់ឈប់សម្រាកព្យាបាលជំងឺ ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឱ្យឈប់ដូចខាងក្រោម៖

ក. ចំពោះមន្ត្រីរាជការស៊ីវិលថ្នាក់រាជធានី ខេត្ត៖

- អភិបាលរាជធានី ខេត្ត ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឱ្យឈប់ពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- អភិបាលរងរាជធានី ខេត្ត មន្ត្រីបម្រើការងារក្នុងរចនាសម្ព័ន្ធសាលារាជធានី ខេត្ត និងអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឱ្យឈប់ពីអភិបាលរាជធានី ខេត្ត
- អភិបាលរងក្រុង ស្រុក ខណ្ឌ មន្ត្រីបម្រើការងារក្នុងរចនាសម្ព័ន្ធសាលាក្រុង ស្រុក ខណ្ឌ ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឱ្យឈប់ពីអភិបាលក្រុង ស្រុក ខណ្ឌ
- ប្រធានមន្ទីរជំនាញរាជធានី ខេត្ត ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឱ្យឈប់ពីក្រសួង ស្ថាប័ន តាមរយៈអភិបាលរាជធានី ខេត្ត

- អនុប្រធានមន្ទីរជំនាញរាជធានី ខេត្ត មន្ត្រីបម្រើការងារក្នុងរចនាសម្ព័ន្ធមន្ទីរជំនាញរាជធានី ខេត្ត និងប្រធាន ការិយាល័យជំនាញក្រុង ស្រុក ខណ្ឌ ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឱ្យឈប់ពីប្រធានមន្ទីរជំនាញរាជធានី ខេត្ត
- អនុប្រធានការិយាល័យជំនាញក្រុង ស្រុក ខណ្ឌ មន្ត្រីបម្រើការងារក្នុងការិយាល័យជំនាញក្រុង ស្រុក ខណ្ឌ ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឱ្យឈប់ពីប្រធានការិយាល័យជំនាញក្រុង ស្រុក ខណ្ឌ។

ខ. ចំពោះមន្ត្រីរាជការស៊ីវិលថ្នាក់ជាតិ ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឱ្យឈប់ពីថ្នាក់ដឹកនាំក្រសួង ស្ថាប័ន។

ច្បាប់ឈប់សម្រាកព្យាបាលជំងឺបន្ទាប់ទៀតលើសពី៣(បី)ខែ ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឱ្យឈប់ពីថ្នាក់ដឹកនាំក្រសួង ស្ថាប័ន។

រាល់ច្បាប់ឈប់សម្រាកព្យាបាលជំងឺដែលអនុញ្ញាតរួចហើយ ត្រូវជូនព័ត៌មានដល់មន្ត្រីទទួលបន្ទុកគ្រប់គ្រងបុគ្គលិកនៃអង្គភាពឬក្រសួង ស្ថាប័នរបស់ខ្លួន។

**មាត្រា ១៤.-**

មន្ត្រីរាជការស៊ីវិលដែលស្ថិតនៅក្រៅក្របខ័ណ្ឌដើមលើសពី៦(ប្រាំមួយ)ខែឡើងទៅ ត្រូវសុំច្បាប់ឈប់សម្រាកព្យាបាលជំងឺនៅក្រសួង ស្ថាប័នដែលខ្លួនកំពុងបំពេញការងារថ្មីនោះ។

ច្បាប់ឈប់សម្រាកព្យាបាលជំងឺ ត្រូវបានបដិសេធចំពោះមន្ត្រីរាជការស៊ីវិលដែលកំពុងស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សតាមពាក្យស្នើសុំលើសពី៦(ប្រាំមួយ)ខែឡើងទៅ។

**មាត្រា ១៥.-**

មន្ត្រីរាជការស៊ីវិលដែលទទួលបានច្បាប់ឈប់សម្រាកព្យាបាលជំងឺរយៈពេល១២(ដប់ពីរ)ខែ ហើយនៅតែពុំអាចមកបម្រើការងារវិញបាន ត្រូវបានដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សដោយបញ្ញត្តិ ហើយប្រសិនបើជំងឺនោះនៅតែព្យាបាលមិនជាទៀត មន្ត្រីរាជការស៊ីវិលសាមីត្រូវបានដាក់ឱ្យបាត់បង់សម្បទាវិជ្ជាជីវៈឬដាក់ឱ្យចូលនិវត្តន៍តាមករណីទីមួយ១ដូចមានចែងក្នុងច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ១៦.-**

មន្ត្រីរាជការស៊ីវិលដែលមានជំងឺឬគ្រោះថ្នាក់ដោយសារការបំពេញការងារឬបំពេញបេសកកម្មដោយមានលិខិតបញ្ជាក់ពីគ្រូពេទ្យមានសមត្ថកិច្ច ត្រូវទទួលបានបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សដូចពេលកំពុងបំពេញការងារដែរ។

## ជំពូកទី៦
## ច្បាប់ឈប់សម្រាកដោយមានកិច្ចការផ្ទាល់ខ្លួន

**មាត្រា ១៧.-**

ច្បាប់ឈប់សម្រាកដោយមានកិច្ចការផ្ទាល់ខ្លួន ត្រូវបានអនុញ្ញាតឱ្យមន្ត្រីរាជការស៊ីវិល ដើម្បីការពារផលប្រយោជន៍ផ្ទាល់ខ្លួននិងគ្រួសារ មានរយៈពេលក្នុងមួយលើកយ៉ាងតិច១(មួយ)ខែ រយៈពេលសរុបមិនឱ្យលើសពី៣(បី)ខែឡើយក្នុងអំឡុងបម្រើការងារជាមន្ត្រីរាជការស៊ីវិល។

ក្នុងករណីឈប់លើសការកំណត់ខាងលើ មន្ត្រីរាជការស៊ីវិលនោះត្រូវបានដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សដោយបញ្ញត្តិ។ បើពិនិត្យឃើញថា មន្ត្រីរាជការស៊ីវិលដែលទទួលបានការអនុញ្ញាតច្បាប់ឈប់សម្រាកដោយមានកិច្ចការផ្ទាល់ខ្លួន ពុំអនុវត្តត្រឹមត្រូវដូចការអះអាងទេនោះ ប្រធានស្ថាប័នត្រូវអញ្ជើញឱ្យមន្ត្រីរាជការស៊ីវិលចូលមកបម្រើការងារវិញជាបន្ទាន់។

ច្បាប់ឈប់សម្រាកដោយមានកិច្ចការផ្ទាល់ខ្លួន ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតឱ្យឈប់ពីថ្នាក់ដឹកនាំក្រសួង ស្ថាប័ន។

**មាត្រា ១៨.-**

មន្ត្រីរាជការស៊ីវិលដែលទទួលបានការអនុញ្ញាតច្បាប់ឈប់សម្រាកដោយមានកិច្ចការផ្ទាល់ខ្លួន ត្រូវទទួលបានបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សចំនួនពាក់កណ្ដាល។

## ជំពូកទី៧
## សមាមិធាននៃច្បាប់ឈប់គ្រប់ប្រភេទ

**មាត្រា ១៩.-**

រាល់ពាក្យស្នើសុំច្បាប់ឈប់គ្រប់ប្រភេទ ត្រូវដាក់ជូនប្រធានអង្គភាពឬក្រសួង ស្ថាប័នតាមឋានានុក្រមនៃមន្ត្រីមានសមត្ថកិច្ច។

រាល់លិខិតអនុញ្ញាតឱ្យឈប់ ត្រូវចុះកាលបរិច្ឆេទនៃការចាប់ផ្ដើមឈប់និងការចូលបម្រើការងារវិញ ដោយមន្ត្រីទទួលបន្ទុកគ្រប់គ្រងបុគ្គលិកនៃអង្គភាពឬក្រសួង ស្ថាប័ននោះ។

**មាត្រា ២០.-**

មន្ត្រីរាជការស៊ីវិលដែលទទួលបានការអនុញ្ញាតច្បាប់ឈប់គ្រប់ប្រភេទ ត្រូវស្ថិតក្នុងស្ថានភាពផ្ដាច់ចេញពីការងាររហូតដល់ថ្ងៃចូលបម្រើការងារវិញ។ ក្នុងករណីចាំបាច់ ប្រធានអង្គភាពឬក្រសួង ស្ថាប័ន មានសិទ្ធិអញ្ជើញមន្ត្រីរាជការស៊ីវិល ដែលទទួលបានការអនុញ្ញាតច្បាប់ឈប់គ្រប់ប្រភេទឱ្យចូលបម្រើការងារវិញ។

**មាត្រា ២១.-**

មន្ត្រីរាជការស៊ីវិលដែលទទួលបានការអនុញ្ញាតច្បាប់ឈប់ប្រចាំឆ្នាំ ច្បាប់ឈប់រយៈពេលខ្លី ច្បាប់ឈប់សម្រាកលំហែមាតុភាព ច្បាប់ឈប់សម្រាកព្យាបាលជំងឺ ត្រូវទទួលបានបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សដូចពេលកំពុងបំពេញការងារដែរ។

**មាត្រា ២២.-**

ថ្នាក់ដឹកនាំក្រសួង ស្ថាប័ន អាចផ្ទេរសិទ្ធិក្នុងការអនុញ្ញាតច្បាប់ឈប់គ្រប់ប្រភេទជូនអង្គភាពក្រោមឱវាទមួយចំនួនតាមការចាំបាច់។

**មាត្រា ២៣.-**

មន្ត្រីរាជការស៊ីវិលជាស្ត្រីដែលមានកូនអាយុក្រោម១(មួយ)ឆ្នាំ មានសិទ្ធិចេញពីធ្វើការ១(មួយ)ម៉ោងមុនពេលកំណត់ក្នុង១(មួយ)ថ្ងៃ។

**មាត្រា ២៤.-**

មន្ត្រីរាជការស៊ីវិលដែលឈប់លើសរយៈពេលនៃការអនុញ្ញាតឱ្យឈប់ ត្រូវទទួលទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។ រយៈពេលនៃការឈប់លើសនេះត្រូវបានលើកលែងប្រសិនបើបណ្ដាលមកពីជំងឺ ឬប្រធានសក្ដិ ឬគ្រោះថ្នាក់ផ្សេងៗ។ ក្នុងករណីនេះ មន្ត្រីរាជការស៊ីវិលសាមីត្រូវជូនដំណឹងជាបន្ទាន់ដល់អង្គភាពឬក្រសួង ស្ថាប័ន ដោយមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ចឬពីគ្រូពេទ្យមានសមត្ថកិច្ច ហើយអាចសុំច្បាប់ឈប់រយៈពេលខ្លីបន្តឬសុំច្បាប់ឈប់ប្រភេទផ្សេងក៏បាន។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**មាត្រា ២៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ២៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ដើម្បីស្នើសុំចុះហត្ថលេខា

**រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ**

ពេជ្រ ប៊ុនធិន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ